# ២៦ - រឿង បុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍



Tablets bei o2
Die neuesten Tablets + Tarif jetzt günstig im Online Shop bestellen.

មានរឿងព្រេងមួយដំណាលថា: មានបុរសកម្ជិលម្នាក់ មានប្រពន្ធគ្រប់លក្ខណ៍ មានកិរិយាមារយាទល្អចេះគោរពប្រណិប័តន៍ប្តី។ តាំងពីបានគ្នាជាប្តីប្រពន្ធមក បុរសកម្ជិលចេះតែពីដេក ដល់ឃ្លានបាយ ទើបក្រោកឡើងស៊ីៗ រួចដេកទៅវិញ សូម្បីថ្នាំជក់ក៏ប្រពន្ធមូរឲ្យដែរប្រពន្ធជាមនុស្សគោរពប្រណិប័តន៍ប្តី មិនមានពាក្យអាក្រក់ទៅលើប្តីសោះ លើកបាយទឹកនិងរបស់អ្វីឲ្យប្តីសុទ្ធតែសំពះ, ដល់ទៅយូរទៅ មានសេចក្តីក្រីក្រខ្លាំងណាស់ នាងនោះរកអ្វីចិញ្ចឹមពុំបានសោះឡើយ, ថ្ងៃមួយនាងរៀបស្លា៥ម៉ាត់ បារី៥ចូលទៅក្រាបសំពះប្តីហើយថា «ខ្ញុំសុំទោសអ្នកប្តី ត្បិតយើងសព្វថ្ងៃក្រណាស់ យើងមិនបានរកស៊ី គ្មានទទួលទានទេ សុំឲ្យអ្នកទៅកាប់ឈើ ធ្វើនង្គ័ល រនាស់ធ្វើស្រែនឹងគេ ត្បិតដល់រដូវធ្វើស្រែហើយ » ។ ប្តីថា «បើដូច្នោះ ឲ្យនាងដាំបាយ វេចជាសំណុំចុះ ប្តីនឹងទៅរកកាប់ឈើធ្វើនង្គ័ល រនាស់ » ។ ប្រពន្ធក្រោកពីយប់ដាំបាយ វេចជាកញ្ចប់ មានទាំងដឹងពូថៅទៅផង ។ បុរស កម្ជិលដេកទាល់តែថ្ងៃរះ ប្រពន្ធពុំហ៊ានដាស់ ចាំឲ្យក្រោកខ្លួនឯង, ដល់ក្រោកហើយ ប្រពន្ធដងទឹក ទៅលប់មុខឲ្យ រួចស្រេចនាងក៏ហុចស្លាបារី នឹងបាយកញ្ចប់ ព្រមទាំងគ្រឿងប្រដាប់ទៅឲ្យប្តី ។ បុរសនោះ ក៏ចុះពីលើផ្ទះទៅ ចូលក្នុងព្រៃរកឈើ, បានឃើញឈើមួយដើម មានមែកសាខាម្លប់ត្រជាក់ ក៏ដាក់បាយសំណុំ ដឹង ពូថៅ ហើយដេកគងអន្ទាក់ខ្លា មើលទៅលើនិយាយតែម្នាក់ឯងថា « មែកឈើនេះ ត្រូវធ្វើជាផ្ទៀងនង្គ័ល, មែកនេះត្រូវធ្វើជាយាម, មែកនេះត្រូវធ្វើជាដង មែកនេះត្រូវជានឹម មែកនេះត្រូវធ្វើជារនាស់ ។គ្រាន់តែដេកថាប៉ុណ្ណឹង ពេលឃ្លានបាយក្រោកឡើងស្រាយបាយសំណុំស៊ីៗរួច ដេកថាដូចមុនទៀត,ថ្ងៃរសៀលត្រឡប់មកផ្ទះវិញ ។ ប្រពន្ធឃើញរត់ទទួលយកគ្រឿងប្រដាប់ នាំប្តីឡើងទៅលើផ្ទះ យកទឹកលាងជើងឲ្យប្តីហើយសួរថា «អ្នកទៅបានការដូចម្តេចខ្លះ ? ប្តីថាមិនទាន់បានទេនាង! ចាំស្អែកសឹមទៅទៀត ដល់កន្លែងដើមឈើនោះហើយ , រុក្ខទេវតាដែលអាស្រ័យនៅទីនោះ ឮបុរសកម្ជិលថាដូច្នោះ ក៏ភ័យ ខ្លាចរកកន្លែងនៅគ្មាន ក៏គិតគ្នានឹងតាមទៅវាយសម្លាប់បុរសកម្ជិលនោះ ឲ្យស្លាប់នៅមាត់ជណ្តើរផ្ទះ កុំឲ្យវាមកកាប់ឈើនេះបាន ។ បុរសនោះក៏ត្រឡប់មកផ្ទះវិញ ។ រុក្ខទេវតា តាមមកដល់មាត់របង ឃើញប្រពន្ធរត់ទៅទទួលប្តីដល់មាត់ជណ្តើរយកទឹកលាងជើងប្តី ។ ដោយសិរីសួស្តីប្រពន្ធនោះ ទេវតាចូលមិនចុះ មិនហ៊ានវាយ។ បុរសនោះរួចពីអន្តរាយក៏ឡើងទៅលើផ្ទះ ប្រពន្ធសួរ និយាយដូចមុនទៀតថា «បានសព្វគ្រប់អស់ហើយ ព្រឹកនឹងទៅកាប់ » ។ ទេវតាភ័យណាស់ថា « បុរសនោះ មុខជាកាប់ហើយព្រឹកនេះ » ក៏នាំគ្នាមកនិយាយអង្វរថា « សុំកុំកាប់ឈើនោះ»។បុរសថា «អញមិនព្រមទេ ព្រឹកនេះអញទៅកាប់ហើយ » ។ ទេវតាភ័យណាស់ ក៏នាំគ្នានិយាយសូក ដោយប្រាប់ទីកន្លែងកំណប់មាសប្រាក់ ឲ្យបុរសៗសួរថា « ឲ្យកំណប់ប៉ុន្មានកន្លែង ? » ។ ទេវតាថាពីរកន្លែង បុរសថា «មិនព្រមទេ, បើ៤កន្លែងទើបព្រម ហើយឲ្យដាក់ឈើសម្គាល់ឲ្យផង »។ ទេវតាក៏ព្រមធ្វើតាម កុំឲ្យតែកាប់ដើមឈើនោះ ។ បុរសថា « បើដូច្នោះ ខ្ញុំលែងកាប់ , តែថាព្រឹកនេះ ខ្ញុំទៅគាស់កំណប់នោះហើយ »។ ទេវតាថា « ទៅចុះខ្ញុំដោតឈើសម្គាល់ទុកឲ្យ »។ ព្រឹកឡើងប្តីប្រពន្ធ នាំគ្នាទៅគាស់កំណប់ដែលទេវតាឲ្យ, ក្នុងកំណប់មួយៗទាំងពីរនាក់ប្តីប្រពន្ធត្រូវជញ្ជូនបីថ្ងៃ បានសុទ្ធតែមាសនិងប្រាក់ចាក់គរពេញផ្ទះ។នាងនោះ ក៏រៀបចំដាក់ហិប ដាក់ឡាំង មិនឲ្យអ្នកណាឃើញ ហើយក៏ជួលជាងឲ្យធ្វើគ្រឿងប្រដាប់ លក់ជាជំនួញរឹតតែមានឡើងៗ បានជាសេដ្ឋី មានមនុស្សកុះករមូលមកនៅពឹងពាក់ជាច្រើន រាប់មិនអស់ ។

**ទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក**

**ផ្ទះធំស្រណុក ត្បិតល័ក្ខណ៍ស្រីជា**

+1 Recommend this on Google

Wunsch-Domains bei STRATO
Die Domain mit den gewissen Extras. Bis 02.08. zum Top-Hoster wechseln!

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

